ឆ្នាំទី៦ លេខ៥៥ ចេញផ្សាយប្រចាំខែមីនា ឆ្នាំ២០១៦

# ព្រឹត្តិបត្រការងារ
# Labour Bulletin

ជាស្ពានរបស់រាជរដ្ឋាភិបាលឆ្ពោះទៅកាន់ ♦ ការងារ ♦ កម្លាំងពលកម្ម ♦ ព័ត៌មានទីផ្សារការងារ ⊕ Government gateway to ♦ Job ♦ Workforce ♦ Labour Market Information




រៀបចំ និងបោះពុម្ពផ្សាយដោយ ទីភ្នាក់ងារជាតិមុខរបរ និងការងារ នៃគណៈកម្មាធិការជាតិបណ្តុះបណ្តាល

ទីភ្នាក់ងារជាតិមុខរបរ និងការងារ
NATIONAL EMPLOYMENT AGENCY

♦ សកម្មភាពថ្មីៗពាក់ព័ន្ធវិស័យការងារ [ទំព័រ១]
♦ ព័ត៌មានទីផ្សារការងារនៅកម្ពុជា [ទំព័រ ៣]
♦ ព័ត៌មានជ្រើសរើសបុគ្គលិក [ទំព័រ ៧]

ទីភ្នាក់ងារជាតិមុខរបរ និងការងារ

ព្រឹត្តិបត្រការងារ

# មាតិកា


## ព័ត៌មាន និងសកម្មភាព

- សកម្មភាពថ្មីៗពាក់ព័ន្ធនឹងវិស័យការងារ និងការអប់រំបណ្តុះបណ្តាល ........ [ទំព័រ ១]

## ព័ត៌មានទីផ្សារការងារនៅកម្ពុជា

- ចំនួនអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិកដែលបានប្រមូលដោយទីភ្នាក់ងារជាតិមុខរបរ និងការងារ ពីខែមករា ឆ្នាំ២០១២ ដល់ខែមីនា ឆ្នាំ២០១៦ [ទំព័រ ៣]

## ព័ត៌មានជ្រើសរើសបុគ្គលិក

- ព័ត៌មានជ្រើសរើសបុគ្គលិកសម្រាប់ខែមីនា ឆ្នាំ២០១៦ ដែលប្រមូលដោយទីភ្នាក់ងារជាតិមុខរបរ និងការងារ [ទំព័រ ៧]


ចំណាងជើងក្របមុខ៖ សកម្មភាពបើកវគ្គបណ្តុះបណ្តាលជំនាញទន់នៅទីភ្នាក់ងារជាតិមុខរបរ និងការងារ

ចំណាងជើងក្របក្រោយ៖ អាសយដ្ឋានទីភ្នាក់ងារជាតិមុខរបរ និងការងារ


## ព្រឹត្តិបត្រការងារ

**គណៈគ្រប់គ្រង**

ឯកឧត្តម ពេជ សោភ័ន
ឯកឧត្តម ប៉ុក ប៉ាន់
ឯកឧត្តម ឡៅ ហ៊ីម
ឯកឧត្តម ហេង សួរ

**នាយកគ្រប់គ្រងទូទៅ**

ឯកឧត្តម ហុង ជឿន

**និពន្ធនាយក**

លោក ហៃ ហ៊ុនឡេង

**និពន្ធនាយករង**

លោក គួច សុមាន
លោក ទូច សុផាត

**ការីនិពន្ធ**

លោកស្រី លី វួចចេង
លោក សុជាតិ កញ្ញារិទ្ធ
កញ្ញា អ៊ូច ជាច័ន្ទមល្លិកា
លោក ស៊ីវ យាង
លោកស្រី ឌី ចង្កុលណី
មន្ត្រីនៃទីភ្នាក់ងារជាតិមុខរបរ និងការងារ

**នាយកគ្រប់គ្រងការផ្សាយ**

លោក គន់ សម្បត្តិ

**នាយកគ្រប់គ្រងការបោះពុម្ព**

លោក គឹម កែវស្មី

**នាយកគ្រប់គ្រងផ្នែករូបភាព និងកុំព្យូទ័រ**

លោក ផូរ ឧស្សាហ៍រចនា

**អ្នករចនាអត្ថបទ**

កញ្ញា ឈា បញ្ញារី
លោក ផែន រដ្ឋា

**អ្នកពិនិត្យ និងកែតម្រូវអក្ខរាវិរុទ្ធ**

មន្ត្រីទីភ្នាក់ងារជាតិមុខរបរ និងការងារ



ព័ត៌មាន និងសកម្មភាព

# សកម្មភាពថ្មីៗ ពាក់ព័ន្ធនឹងវិស័យការងារ និងអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

## វេទិកាការងារស្តីពី «ឱកាសការងារ និងកម្មសិក្សាការងារ»



**ភ្នំពេញ៖** កាលពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៦ កន្លងទៅនេះ មជ្ឈមណ្ឌលការងាររាជធានីភ្នំពេញបានធ្វើការរៀបចំវេទិកាការងារមួយ ដែលស្ថិតក្រោមប្រធានបទ «ឱកាសការងារ និងកម្មសិក្សាការងារ» នៅអគារទីភ្នាក់ងារជាតិមុខរបរ និងការងារ ដែលក្នុងកម្មវិធីវេទិកានេះទទួលបានការចូលរួមពីសំណាក់សាធារណៈជន សិស្ស-និស្សិត និងអ្នកស្វែងរកការងារធ្វើចំនួន ៦១នាក់។ គោលបំណងនៃការរៀបចំវិទិកាការងារនេះឡើង គឺដើម្បីបង្កើតឱ្យមានការជួបគ្នាដោយផ្ទាល់រវាងអ្នកស្វែងរកការងារធ្វើនិយោជក អ្នកផ្តល់ការអប់រំបណ្តុះបណ្តាល និងដៃគូពាក់ព័ន្ធនានា សំដៅរួមចំណែកដោះស្រាយបញ្ហាតម្រូវការការងារ ជំនាញ និងកម្លាំងពលកម្មនាពេលបច្ចុប្បន្ន ស្របតាមគោលនយោបាយយុទ្ធសាស្ត្រចតុកោណ«ដើម្បីកំណើនការងារ សមធម៌ និប្រសិទ្ធភាពនៅកម្ពុជា» ដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងនីតិកាលទី៥ នៃរដ្ឋសភា។ ជាក់ស្តែងវេទិកានេះទទួលបានការសហការចូលរួមផ្សព្វផ្សាយ និងធ្វើការសម្ភាសជ្រើសរើបុគ្គលិកនៅនឹងកន្លែងពីសំណាក់គ្រឹះស្ថានសហគ្រាសធំៗ ចំនួន0៣គឺ ក្រុមហ៊ុន Park Café, ធនាគារមេគង្គ និងក្រុមហ៊ុន BIMA ដើម្បីចូលរួមធ្វើជាវាគ្មិនចែករំលែកបទពិសោធន និងផ្តល់ឱកាសការងារ កម្មសិក្សាការងារ ដោយងាយស្រួលនៅនឹងកន្លែងចំនួន ៤០៥ កន្លែងផងដែរ។


តទៅទំព័របន្ទាប់

## សិក្ខាសាលាស្តីពី «ការរៀបចំផែនការអាជីព និងការជ្រើសរើសជំនាញសិក្សា»

ភ្នំពេញ៖ ដើម្បីបង្ខិតសេវាសាធារណៈអោយកាន់តែជិតអ្នកប្រើប្រាស់ និងក្នុងគោលបំណងពង្រីកវិសាលភាពនៃការផ្តល់សេវាបន្ថែមទៀត មជ្ឈមណ្ឌលការងាររាជធានីភ្នំពេញ នៃទីភ្នាក់ងារជាតិមុខរបរ និងការងារ បានធ្វើការរៀបចំសិក្ខាសាលាស្តីពី«ការរៀបចំផែនការអាជីព និងការជ្រើសរើសជំនាញសិក្សា» ដែលប្រព្រឹត្តទៅនាថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៦ នៅវិទ្យាល័យព្រែកឯង និងវិទ្យាល័យព្រែកថ្មី ដែលមានការចូលរួមពីសំណាក់សិស្សប្រមាណជាង ២០០នាក់។ គោលបំណងនៃការរៀបចំសិក្ខាសាលានេះ គឺដើម្បីបង្ហាញឱ្យឃើញថា ការសម្រេចចិត្តជ្រើសរើសមុខវិជ្ជាឯកទេសថ្ងៃនេះ គឺមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅ នឹងឱកាសការងារនាពេលអនាគត់ ។ ក្នុងនោះដែរមន្ត្រីផ្តល់សេវាជួរមុខ របស់មជ្ឈមណ្ឌលការងាររាជធានីភ្នំពេញបានបន្ថែមអោយដឹងថា "សិស្សានុសិស្សដែលកំពុងស្ថិតក្នុងថ្នាលអប់រំបំណេះទូទៅកម្រិតមធ្យមសិក្សាទុតិយភូមិ នឹងត្រូវការសម្រេចចិត្តជ្រើរើសមុខវិជ្ជាឯកទេស ដើម្បីបន្តការសិក្សានៅកម្រិតឧត្តមសិក្សា ឬការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។ ការសម្រេចចិត្តលើផ្នែកនេះ មិនមែនជាការងាយស្រួលនោះទេពីព្រោះសិស្សានុសិស្សម្នាក់ៗត្រូវធ្វើការស្វែងយល់ឱ្យបានស៊ីជម្រៅអំពីកត្តាពាក់ព័ន្ធនានាមានជាអាទិ៍៖ ការស្វែងយល់ពី«កត្តាផ្ទាល់ខ្លួន» ដោត្រូវពិនិត្យលើចំណូលចិត្ត ជំនាញ គុណតម្លៃ និងបុគ្គលិកលក្ខណៈ ដែលស័ក្តិសមសម្រាប់ការសិក្សាមុខវិជ្ជានីមួយៗ។ បន្ថែមលើនេះត្រូវពិនិត្យលើ«កត្តាទីផ្សារការងារ» ដែលពាក់ព័ន្ធ នឹងតម្រូវការ ឬកង្វះខាតនៃប្រភពជំនាញពីភាគីនិយោជក ហេតុនេះការរៀបចំផែនការអាជីពបានត្រឹមត្រូវ នឹងជួយបង្កើនសក្តានុពលឱ្យចូលទីផ្សារការងារកាន់តែងាយស្រួល "។



## វគ្គបណ្តុះបណ្តាលស្តីពី «ជំនាញទន់»

**ភ្នំពេញ៖** កាលពីថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦ កន្លងទៅនេះ មជ្ឈមណ្ឌលការងាររាជធានីភ្នំពេញបានរៀបចំវគ្គបណ្តុះបណ្តាលខ្លីរយៈពេលមួយថ្ងៃ ស្តីពី «ជំនាញទន់» ជូនដល់អ្នកស្វែងរកការងារធ្វើរបស់យើងចំនួន ២៥ នាក់ (ស្រី ១៤ នាក់)។ គោលបំណងនៃការរៀបចំវគ្គបណ្តុះបណ្តាលនេះឡើង គឺដើម្បីឆ្លើយតបនឹងតម្រូវការជំនាញរបស់និយោជក ចំពោះ អ្នកស្វែងរកការងារធ្វើបច្ចុប្បន្ន។ ក្នុងវគ្គបណ្តុះបណ្តាលនេះ NEA ផ្តល់ជូនអ្នកចូលរួមរបស់ខ្លួនជាបឋមនូវបំនិនជាមូលដ្ឋានចំនួនបី៖ ជំនាញក្នុងការទំនាក់ទំនង ជំនាញក្នុងការដោះស្រាយបញ្ហា និងជំនាញក្នុងការធ្វើការងារជាក្រុម។ សម្រាប់អ្នកស្វែងរកការងារធ្វើដែលមានចំណាប់អារម្មណ៍ចង់ចូលរួមវគ្គបណ្តុះបណ្តាលនេះ អាចទំនាក់ទំនង ចុះឈ្មោះបានតាមរយៈទូរសព្ទលេខ ០២៣ ៦៣៥ ៧១ ៧៧ ឬលេខ ០៩៧ ៥០៩ ០៦០៦ រៀងរាល់ម៉ោងធ្វើការ។ (បញ្ជាក់៖ វគ្គបណ្តុះបណ្តាលនេះ ផ្តល់ជូនដោយឥតគិតថ្លៃ និងទទួលត្រឹម ២៥ នាក់ប៉ុណ្ណោះក្នុងមួយវគ្គ។)




ព័ត៌មានទីផ្សារការងារ

# ព័ត៌មានទីផ្សារការងារនៅកម្ពុជា

## ចំនួនអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិក ដែលបានប្រមូលដោយទីភ្នាក់ងារជាតិមុខរបរនិងការងារ ពីខែមករា ឆ្នាំ២០១២ ដល់ ខែមីនា ឆ្នាំ២០១៦

អត្ថបទនេះមានបំណងបង្ហាញពីតម្រូវការ និងការផ្គត់ផ្គង់កម្លាំងពលកម្មនាពេលបច្ចុប្បន្ន ក្នុងទីផ្សារការងារកម្ពុជា តាមរយៈទិន្នន័យស្ថិតិអ្នកចុះឈ្មោះស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិក ដែលបានប្រមូលដោយទីភ្នាក់ងារជាតិមុខរបរ និងការងារ (ទ.ជ.ម.ក) ចាប់ពីខែមករា ឆ្នាំ២០១២ ដល់ខែមីនា ឆ្នាំ២០១៦។ ទិន្នន័យទាំងនោះរួមមានអ្នកចុះឈ្មោះស្វែងរកការងារធ្វើចំនួន ២៤.០៣១នាក់ (មិនរួមបញ្ចូលអ្នកស្វែងរកការងារធ្វើ ដែលបានប្រមូលនៅតាមមូលដ្ឋាន) និងព័ត៌មានជ្រើសរើសបុគ្គលិកចំនួន ២០៩.៨៤៨នាក់។ ជាថ្មីម្តងទៀត ទ.ជ.ម.ក សូមបញ្ជាក់ថាទិន្នន័យដែលបាន និងកំពុងលើកយកមកបង្ហាញជូនក្នុងផ្នែកនេះ គឺមិនគ្របដណ្តប់លើទិន្នន័យសម្រាប់ប្រទេសកម្ពុជាទាំងមូលទេ ដូច្នេះរាល់ការប្រើប្រាស់ និងការបកស្រាយទិន្នន័យទាំងនេះត្រូវពិចារណានូវបញ្ហានេះ។

## ១. ចំនួនអ្នកស្វែងរកការងារធ្វើនិងព័ត៌មានជ្រើសរើសបុគ្គលិកបែងចែកតាមក្រុមចំណាត់ថ្នាក់មុខរបរ ISCO (ខែមករា ឆ្នាំ២០១២ - ខែមីនា ឆ្នាំ២០១៦)

ដើម្បីធ្វើការបង្ហាញអំពីស្ថានភាពទីផ្សារការងារមួយ យើងចាំបាច់ត្រូវតែធ្វើការពិចារណាទៅលើតម្រូវការ និងការផ្គត់ផ្គង់នៃកម្លាំងពលកម្មនៅក្នុងទីផ្សារនេះ។ ប៉ុន្តែការវិភាគ ពិចារណាពីកម្លាំងពលកម្មអាចធ្វើឡើងក្នុងទម្រង់ និងរូបភាពច្រើនសណ្ឋាន។ ក្នុងចំនុចនេះ ទីភ្នាក់ងារជាតិមុខរបរ និងការងារ (ទ.ជ.ម.ក) សូមលើកយកការប្រៀបធៀបរវាងចំនួនអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិក ដោយបែងចែកតាមក្រុមចំណាត់ថ្នាក់មុខរបរ (ISCO) មកធ្វើការបង្ហាញជូន។ បើពិនិត្យមើលទៅលើក្រុមចំណាត់ថ្នាក់មុខរបរធំបំផុត (Major Occupation) ដែលបានបង្ហាញជូនក្នុងរូបទី១(ទំព័របន្ទាប់) ឃើញថាក្រុមដែលមានការផ្គត់ផ្គង់កម្លាំងពលកម្មច្រើនជាងគេ គឺក្រុមអ្នកជំនាញឯកទេសវិជ្ជាជីវៈដែលមានអត្រារហូតដល់ ៣១,៥% នៃចំនួនអ្នកស្វែងរកការងារធ្វើសរុបដែលប្រមូលដោយទីភ្នាក់ងារ ជាតិមុខរបរ និងការងារ ចំណែកតម្រូវការកម្លាំងពលកម្មសម្រាប់ក្រុមជំនាញដូចគ្នានេះ គឺមានត្រឹមតែ ៨,៤% ប៉ុណ្ណោះ។ បើពិនិត្យមើលទៅលើផ្នែកតម្រូវការកម្លាំងពលកម្មវិញឃើញថាក្រុមដែលមានតម្រូវការខ្ពស់ជាងគេ គឺកម្មករជំនាញផ្នែកសិប្បកម្ម និងកម្មករជំនាញពាក់ព័ន្ធ ដែលមានអត្រារហូតដល់៤០,៣% នៃតម្រូវការកម្លាំងពលកម្មសរុបដែលបានប្រមូលដោយ ទ.ជ.ម.ក រីឯការផ្គត់ផ្គង់កម្លាំងពលកម្មសម្រាប់ក្រុមចំណាត់ថ្នាក់មុខរបរដូចគ្នានេះមានត្រឹមតែ ៧,៥% ប៉ុណ្ណោះ។


តទៅទំព័របន្ទាប់

រូបទី១ ចំនួនអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិកបែងចែកតាមក្រុមចំណាត់ថ្នាក់មុខរបរ ISCO (ខែមករា ឆ្នាំ២០១២ - ខែមីនា ឆ្នាំ២០១៦)




សម្គាល់៖ អ្នកស្វែងរកការងារធ្វើសរុបចំនួន ២៤.០៣១នាក់ និងព័ត៌មានជ្រើសរើសបុគ្គលិកចំនួន ២០៩.៨៤៨នាក់

## ២. ចំនួនអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិកបែងចែកតាមចំណាត់ថ្នាក់សហគ្រាសនៃសកម្មភាពសេដ្ឋកិច្ច (ខែមករា ឆ្នាំ២០១២ - ខែមីនា ឆ្នាំ២០១៦)

បើពិនិត្យមើលទៅលើចំនួនអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិក ដោយបែងចែកទៅតាមវិស័យធំៗទាំងបីនៃសកម្មភាពសេដ្ឋកិច្ច យើងចាប់អារម្មណ៍ឃើញថាការផ្គត់ផ្គង់កម្លាំងពលកម្ម បានប្រមូលផ្តុំនៅក្នុងវិស័យសេវាកម្ម តាមពីក្រោយរៀងគ្នាដោយវិស័យឧស្សាហកម្ម និងកសិកម្ម ខណៈតម្រូវការកម្លាំងពលកម្មក្នុងវិស័យឧស្សាហកម្មមានកម្រិតខ្ពស់ជាងគេ (រូបទី២)។ ក្នុងនោះ យើងសង្កេតឃើញថានៅក្នុងវិស័យសេវាកម្ម ចំនួនអ្នកស្វែងរកការងារធ្វើ (ផ្នែកផ្គត់ផ្គង់កម្លាំងពលកម្ម) មានអត្រា ៥៤,០%ខ្ពស់ជាងព័ត៌មានជ្រើសរើសបុគ្គលិក (ផ្នែកតម្រូវការកម្លាំងពលកម្ម)ដែលមានអត្រា ៤០,៥%ប៉ុណ្ណោះ។ ចំណែកវិស័យឧស្សាហកម្មវិញ ឃើញថាព័ត៌មានជ្រើសរើសបុគ្គលិក (ផ្នែកតម្រូវការកម្លាំងពលកម្ម) មានអត្រាប្រមាណ ៥៦,៨% ចំណែកឯចំនួនអ្នកស្វែងរកការងារធ្វើ (ផ្នែកផ្គត់ផ្គង់កម្លាំងពលកម្ម) ក្នុងវិស័យនេះវិញមានអត្រាត្រឹមតែ ១៥,៣%។

រូបទី២ ចំនួនអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិក បែងចែកតាមវិស័យសេដ្ឋកិច្ច (ខែមករា ឆ្នាំ២០១២ ខែមីនា ឆ្នាំ២០១៦)

សម្គាល់៖ អ្នកស្វែងរកការងារធ្វើសរុបចំនួន ២៤.០៣១នាក់ និងព័ត៌មានជ្រើសរើសបុគ្គលិកចំនួន ២០៩.៨៤៨នាក់



តារាងទី១ ចំនួនអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិកបែងចែកតាមចំណាត់ថ្នាក់សហគ្រាសនៃសកម្មភាពសេដ្ឋកិច្ច
(ខែមករា ឆ្នាំ២០១២ - ខែមីនា ឆ្នាំ២០១៦)

| ចំណាត់ថ្នាក់នៃសហគ្រាស | | អ្នកស្វែងរកការងារធ្វើ | | ព័ត៌មានជ្រើសរើសបុគ្គលិក | |
|---|---|---|---|---|---|
| | | ចំនួន | ភាគរយ (%) | ចំនួន | ភាគរយ (%) |
| A | កសិកម្ម និងរុក្ខាប្រមាញ់ | 420 | 1.7 | 4,117 | 2.0 |
| B | រ៉ែ និងថ្ម | 13 | 0.1 | 196 | 0.1 |
| C | កម្មន្តសាល | 2,882 | 12.0 | 110,385 | 52.6 |
| D | អគ្គិសនី ឧស្ម័ន ចំហាយ និងផ្គត់ផ្គង់ម៉ាស៊ីនត្រជាក់ | 714 | 3.0 | 8,348 | 4.0 |
| E | ផ្គត់ផ្គង់ទឹក លូទឹក គ្រប់គ្រងសំរាម និងសកម្មភាពផ្សេងៗ | 76 | 0.3 | 342 | 0.2 |
| F | សំណង់ | 283 | 1.2 | 2,928 | 1.4 |
| G | លក់ដុំ និងរាយ | 903 | 3.8 | 6,630 | 3.2 |
| H | ដឹកជញ្ជូន ស្តុក និងឃ្លាំង | 133 | 0.6 | 959 | 0.5 |
| I | សណ្ឋាគារ ការស្នាក់អាស្រ័យ អាហារ ភេសជ្ជៈ និងសេវាផ្សេងៗ | 1,391 | 5.8 | 14,872 | 7.1 |
| J | ព័ត៌មាន និងទូរគមនាគមន៍ | 1,124 | 4.7 | 7,381 | 3.5 |
| K | ហិរញ្ញវត្ថុ និងធានារ៉ាប់រង | 3,266 | 13.6 | 21,426 | 10.2 |
| L | អចលនទ្រព្យ | 42 | 0.2 | 550 | 0.3 |
| M | វិជ្ជាជីវៈ បច្ចេកទេស និងវិទ្យាសាស្ត្រ | 1,831 | 7.6 | 2,721 | 1.3 |
| N | រដ្ឋបាល និងសេវាគាំទ្រ | 715 | 3.0 | 3,219 | 1.5 |
| O | រដ្ឋបាលសាធារណៈ និងការពារ | 225 | 0.9 | 2,023 | 1.0 |
| P | អប់រំ | 1,453 | 6.0 | 6,831 | 3.3 |
| Q | សុខភាព និងសេវាសង្គម | 530 | 2.2 | 2,068 | 1.0 |
| R | សិល្បៈ ការកំសាន្ត និងការច្នៃប្រឌិត | 28 | 0.1 | 3,201 | 1.5 |
| S | សេវាផ្សេងៗ | 796 | 3.3 | 7,613 | 3.6 |
| T | សកម្មភាពជានិយោជកនៅក្នុងផ្ទះដោយប្រកបអាជីវកម្ម ឬសេវាផ្សេងៗ | 32 | 0.1 | 355 | 0.2 |
| U | សកម្មភាពរបស់ស្ថានទូត កុងស៊ុល និងអង្គការអន្តរជាតិ | 216 | 0.9 | 2,190 | 1.0 |
| V | ផ្សេងៗ | 6,958 | 29.0 | 1,493 | 0.7 |
| **សរុប** | | 24,031 | 100.0 | 209,848 | 100.0 |

សម្គាល់៖ អ្នកស្វែងរកការងារធ្វើសរុបចំនួន ២៤.០៣១នាក់ និងព័ត៌មានជ្រើសរើសបុគ្គលិកចំនួន ២០៩.៨៤៨នាក់

## ៣. ចំនួនអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិកបែងចែកតាមកម្រិតអប់រំបណ្តុះបណ្តាល (ខែមករា ឆ្នាំ២០១២ - ខែមីនា ឆ្នាំ២០១៦)

*ដោយផ្អែកលើទិន្នន័យនៃចំនួនអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិកដែលប្រមូលដោយទីភ្នាក់ងារជាតិមុខរបរ និងការងារ ដោយបែងចែកតាមកម្រិតអប់រំ (រូបទី៣) ឃើញថាអ្នកស្វែងរកការងារធ្វើ (ផ្នែកផ្គត់ផ្គង់កម្លាំងពលកម្ម) មួយភាគធំ ប្រមាណជា ៤៨,៩% កាន់សញ្ញាបត្របរិញ្ញាបត្រ ចំណែកឯព័ត៌មានជ្រើសរើសបុគ្គលិក (ផ្នែកតម្រូវការកម្លាំងពលកម្ម) កម្រិតបរិញ្ញាបត្រវិញមានត្រឹមតែ ១៣,៨% ប៉ុណ្ណោះ។ បើពិនិត្យមើលទៅលើព័ត៌មានជ្រើសរើសបុគ្គលិក (ផ្នែកតម្រូវការកម្លាំងពលកម្ម) វិញឃើញថា តម្រូវការកម្លាំងពលកម្មមួយភាគធំ គឺមិនទាមទារឱ្យមានបញ្ចប់ថ្នាក់សិក្សាណាមួយឡើយ ដែលមានអត្រារហូតដល់ ៦៤,៥% ដែលជាអត្រាមួយខ្ពស់ខ្លាំង បើប្រៀបធៀបជាមួយនឹងចំនួនអ្នកស្វែងរកការងារធ្វើ ដែលមានកម្រិតអប់រំដូចគ្នានេះមានត្រឹមតែ ១៤,១%ប៉ុណ្ណោះ។*

រូបទី៣ ចំនួនអ្នកស្វែងរកការងារធ្វើ និងព័ត៌មានជ្រើសរើសបុគ្គលិក បែងចែកតាមកម្រិតអប់រំបណ្តុះបណ្តាល (ខែមករា ឆ្នាំ២០១២ - ខែមីនា ឆ្នាំ២០១៦)




សម្គាល់៖ អ្នកស្វែងរកការងារធ្វើសរុបចំនួន ២៤.០៣១នាក់ និងព័ត៌មានជ្រើសរើសបុគ្គលិកចំនួន ២០៩.៨៤៨នាក់

*អត្ថបទស្តីពី ព័ត៌មានទីផ្សារការងារនៅកម្ពុជា រៀបចំ និងបកស្រាយពន្យល់ដោយ **ការិយាល័យស្រាវជ្រាវ វិភាគ និងព្យាករណ៍ព័ត៌មានទីផ្សារការងារ** យោងតាមមូលដ្ឋានទិន្នន័យដែលប្រមូលដោយទីភ្នាក់ងារជាតិមុខរបរ និងការងារ។*



ព័ត៌មានជ្រើសរើសបុគ្គលិក

# ព័ត៌មានជ្រើសរើសបុគ្គលិក

## VACANCY ANNOUNCEMENT

## ដើម្បីទទួលបានសេវាការងារដោយ «ឥតគិតថ្លៃ» សូមទំនាក់ទំនង ឬធ្វើដំណើរមកកាន់៖

លោកអ្នកដែលមានបំណងដាក់ពាក្យសុំការងារ និងចង់ដឹងព័ត៌មានអំពីឱកាសការងារជាច្រើនប្រភេទផ្សេងទៀតអាចទំនាក់ទំនងមកកាន់ □**មជ្ឈមណ្ឌលការងារ**□ ណាមួយរបស់ទីភ្នាក់ងារជាតិមុខរបរ និងការងារ ឬអាចស្វែងរក និងទាញយកព័ត៌មានទាំងអស់នេះ ពីគេហទំព័ររបស់យើង www.nea.gov.kh/jobshop

**ម.ក រាជធានីភ្នំពេញ**
ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
023 633 6002 ឬ 077 232 378 ឬ016 786 655
jc_pp@nea.gov.kh

**ម.ក ខេត្តបាត់ដំបង**
វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែន បាត់ដំបង ផ្លូវលេខ២០១ ភូមិព្រែកមហាទេព សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង
053 733 111 ឬ 016 926 655
jc_battambang@nea.gov.kh

**ម.ក ខេត្តកំពត**
វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែន កំពត ភូមិ០១ ឧសភា សង្កាត់កំពង់កណ្តាល ក្រុងកំពត
033 210 277 ឬ 016 506 655
jc_kampot@nea.gov.kh

**ម.ក ខេត្តកំពង់ចាម**
មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ចាម ផ្លូវលេខ៧ចាស់ ភូមិទី៧ សង្កាត់កំពង់ចាម ក្រុងកំពង់ចាម
042 210 277 ឬ 016 656 655
jc_kampongcham@nea.gov.kh

**ម.ក ខេត្តសៀមរាប**
វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែន សៀមរាប សង្កាត់ស្លក្រាម ក្រុងសៀមរាប
063 210 277ឬ 016 536 655
jc_siemreap@nea.gov.kh

**ម.ក ខេត្តស្វាយរៀង**
វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែន ស្វាយរៀង ភូមិមេភ្លើង សង្កាត់ស្វាយរៀង ក្រុងស្វាយរៀង
044 715 277 ឬ 016 646 655
jc_svayrieng@nea.gov.kh

**ម.ក ខេត្តកំពង់ធំ**
មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ធំ ភូមិអាចារ្យលាក់ សង្កាត់ អាចារ្យលាក់ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ
062 210 277 / 016 836 655
jc_kampongthom@nea.gov.kh

**ម.ក ខេត្តព្រៃវែង**
មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តព្រៃវែង ភូមិ១សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង
081 786 655 / 043 210 277
jc_preyveng@nea.gov.kh

**ម.ក ខេត្តតាកែវ**
វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែន តាកែវ ក្នុងភូមិ៣ សង្កាត់រការក្នុង ក្រុងដូនកែវ ខេត្តតាកែវ
032 210 277 ឬ 016 676 655
jc_takeo@nea.gov.kh



ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ / 023 884 692 ឬ 088 678 5678 / info@nea.gov.kh

**ឥឡូវនេះ អតិថិជនរបស់ □□□□□□ អាចធ្វើការហៅចូលដោយ □ឥតគិតថ្លៃ□ មកកាន់មជ្ឈមណ្ឌលការងារណាមួយក៏បាន ដើម្បីសាកសួរព័ត៌មានបន្ថែម!**

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកកាន់ «មជ្ឈមណ្ឌលការងារ» ណាមួយរបស់ ទ.ជ.ម.ក ឬតាមរយៈគេហទំព័រ www.nea.gov.kh/jobshop

## INTERMEDICA Co., Ltd.

**ថ្ងៃផុតកំណត់:** ០៧ មេសា ២០១៦

**ទីកន្លែងធ្វើការ:** ភ្នំពេញ

**មុខតំណែង:**

១. អ្នកបើឡាន (ចំនួន ០៣នាក់)

**លក្ខខណ្ឌជ្រើសរើស:**

- ភេទប្រុស អាយុពី20-50ឆ្នាំ
- ចេះបើកបរឡាន និងមានបណ្ណ័បើកបរត្រឹមត្រូវ
- ចេះអានឯកសារ ដូចជា វិកយ័បត្រ័ បណ្ណ័បញ្ចេញទំនិញ ជាអក្សរឡាតាំង
- មានចរិកស្លូតបូត ស្មោះត្រង់

**សូមទំនាក់ទំនងតាមរយ:**

ផ្ទះលេខ៥៤ ផ្លូវ៥៩៨ ខណ្ឌទួលគោក រាជធានីភ្នំពេញ

០១២ ៦៦៦ ៨៩៧

home@intermed.com.kh

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

## Mekong NE Marketing Co., Ltd

**ថ្ងៃផុតកំណត់:** ០៨ មេសា ២០១៦

**ទីកន្លែងធ្វើការ:** ភ្នំពេញ

**មុខតំណែង:**

១. ផ្នែកលក់ (ចំនួន ១៥នាក់)

**លក្ខខណ្ឌជ្រើសរើស:**

- បុគ្គលិកទាំងពីរភេទ
- មានបទពិសោធន៍ក្នុងការលក់ពី ១ឆ្នាំឡើងទៅ
- អាចប្រើប្រាស់ភាសាអង់គ្លេសបាន
- មានភាពស្មោះត្រង់ ក្លាហាន និងគោរពពេលវេលា
- មានភាពឆ្លាតវៃក្នុងការដោះស្រាយបញ្ហា
- មានភាពអំណត់ និងទទួលខុសត្រូវក្នុងការងារខ្ពស់

**សូមទំនាក់ទំនងតាមរយ:**

ផ្ទះលេខ ៤A-៥A ផ្លូវ២៦៥ សង្កាត់ទឹកល្អក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ

០២៣ ៦៣៨ ១៣៣២

mekongne@gmail.com

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

## Human Relation Organization H.R.O

**ថ្ងៃផុតកំណត់:** ០៦មេសា ២០១៦

**ទីកន្លែងធ្វើការ:** សៀមរាប

**មុខតំណែង:**

១. មន្ត្រីឥណទាន (ចំនួន ១៦នាក់)

**លក្ខខណ្ឌជ្រើសរើស:**

- អាយុចាប់ពី ២០ឆ្នាំឡើងទៅ។
- សិស្សប្រឡងធ្លាក់បាក់ឌុបក៏អាចដាក់បាន។
- កំពុងរៀន ឬបញ្ចប់ថ្នាក់បរិញ្ញាបត្រ កាន់តែប្រសើរ។
- មានការប្រឹងប្រែងតស៊ូក្នុងការងារ។
- មានចិត្តស្មោះត្រង់។
- មានគំនិតច្នៃប្រឌិត និងទទួលយកចំណេះដឹងថ្មីៗ។
- មានម៉ូតូផ្ទាល់ខ្លួន។

**សូមទំនាក់ទំនងតាមរយ:**

ផ្ទះលេខB03 ផ្លូវ អ៊ុង អឿន ភូមត្រពាំងសេះ សង្កាត់គោកចក (បុរីប្រិម៍ប្រីយ៍) ក្រុងសៀមរាប

០៦៣ ៦៣៨៨ ៨៥៧

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកកាន់ «មជ្ឈមណ្ឌលការងារ» ណាមួយរបស់ ទ.ជ.ម.ក ឬតាមរយៈគេហទំព័រ www.nea.gov.kh/jobshop

## Singha & Leo Beer

**ថ្ងៃផុតកំណត់:** ១២ មេសា ២០១៦

**ទីកន្លែងធ្វើការ:** ភ្នំពេញ

**មុខតំណែង:**

១. អ្នកបើឡាន (ចំនួន ០៥នាក់)

**លក្ខខណ្ឌជ្រើសរើស:**

- មានប័ណ្ណបើកបរដែលមានសុពលភាព
- មានបទពិសោធន៍យ៉ាងតិច១ឆ្នាំ
- ចេះអក្សរ និងគិតលេខ
- ស្រឡាញ់ការងារ ស្មោះត្រង់ និងគោរពពេលវេលាធ្វើការ

**សូមទំនាក់ទំនងតាមរយៈ:**

ផ្ទះលេខ២៦៣ ផ្លូវ២៤២ សង្កាត់ចាក់តុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

០២៣ ៩៩០ ៦៥៧

Syneng.ung@cp-a.com.kh

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

## Chip Mong Group

**ថ្ងៃផុតកំណត់:** ២១ មេសា ២០១៦

**ទីកន្លែងធ្វើការ:** ភ្នំពេញ

**មុខតំណែង:**

១. អ្នកបើកបរឡានស្ទូច
២. អ្នកបកឡានបាញ់បេតុង
៣. សន្តិសុខ
៤. ចុងភៅ
៥. កូនកាំបិត
៦. ប្រធានអនាម័យ
៧. អ្នកអនាម័យ
៨. ប្រធានអគារ

**លក្ខខណ្ឌជ្រើសរើស:**

- ត្រូវចេះអាន និងសរសេរភាសាខ្មែរ
- អាយុចាប់ពី១៨ ដល់៤៥ឆ្នាំ
- ត្រូវមានប័ណ្ណបើកបរសម្រាប់មុខតំណែងអ្នកបើកបរ
- សម្រាប់សន្តិសុខត្រូវមានកំពស់ចាប់ពី ១.៦៥ម៉ែត្រឡើងទៅ
- មានកាយសម្បទាមាំមួន អត្តចរិកស្មោះត្រង់
- មានទំនាក់ទំនងល្អជាមួយអ្នកដទៃ

**សូមទំនាក់ទំនងតាមរយៈ:**

ផ្ទះលេខ១៣៧បេ ផ្លូវម៉ៅសេទុង សង្កាត់បឹងកក់៣ ខណ្ឌចំការមន រាជធានីភ្នំពេញ

០៨៩ ៥៩៣ ២២២ / ០៩៨ ៦៦៦ ៨៣៧

hr@chipmonggroup.com

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

## ECO PARTS CO., LTD

**ថ្ងៃផុតកំណត់:** ១២ មេសា ២០១៦

**ទីកន្លែងធ្វើការ:** ភ្នំពេញ

**មុខតំណែង:**

១. ជាងម៉ាស៊ីនផលិតកម្ម និងពុម្ពដែរ

**លក្ខខណ្ឌជ្រើសរើស:**

- ត្រូវមានបទពិសោធន៍ការងារយ៉ាងតិច ៣ឆ្នាំ
- មានបទពិសោធន៍ទាក់ទងការដេរ
- មានការច្នៃប្រឌិតខ្ពស់
- អាចយល់ពីអក្សរអង់គ្លេសបន្តិចបន្តួចកាន់តែប្រសើរ

**សូមទំនាក់ទំនងតាមរយៈ:**

អាគារទី៥ឌី សួនឧស្សាហកម្មជីនយ៉ុងផាង ផ្លូវជាតិលេខ៣ ភូមិស្រែញ៉រ សង្កាត់ពងទឹក ខណ្ឌដង្កោ រាជធានីភ្នំពេញ

០៨១ ៩៩៩ ៩៤០

Em.panhavadh@ecopartscambodia.com

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកកាន់ «មជ្ឈមណ្ឌលការងារ» ណាមួយរបស់ ទ.ជ.ម.ក ឬតាមរយៈគេហទំព័រ www.nea.gov.kh/jobshop

## ហាយប្រ៊ីដ សឹបផ្លាយ អេន សេល ខូអិលធីឌី

**ថ្ងៃផុតកំណត់:** ០១ មេសា ២០១៦

**ទីកន្លែងធ្វើការ:** ភ្នំពេញ

**មុខតំណែង:**

១. ផ្នែកលក់

**លក្ខខណ្ឌជ្រើសរើស:**

- មានសញ្ញាប័ត្រផ្នែកកសិកម្ម ឬសញ្ញាប័ត្រមានតម្លៃស្មើ
- បើមានបទពិសោធន៍ផ្នែកទីផ្សារ កាន់តែប្រសើរ
- ត្រូវមានយានជំនិះផ្ទាល់ខ្លួន
- មានកុំព្យូទ័រ Laptop ផ្ទាល់ខ្លួន
- ត្រូវមានធន្ទ: និងតស៊ូអត់ធ្មត់នឹងការងា
- អាចធ្វើការតាមខេត្តបាន
- មានជំនាញទំនាក់ទំនង ជាមួយអតិថិជន
- អាចប្រើកម្មវិធី Ms Word Excel Internet Email បាន ច្បាស់លាស់

**សូមទំនាក់ទំនងតាមរយៈ:**

ផ្ទះលេខ២២៩៣សេ ផ្លូវណតប្រ៊ីជ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ ជាប់សាលាអាមេរិកខាមប្រ៊ីជ

☎ ០២៣ ៩៦៩ ៧១២/០៧១ ៣៨៨៨ ០៣៧

✉ Hr010.hybrid@gmail.com

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

## JOBRIDGE

**ថ្ងៃផុតកំណត់:** ២៧ មេសា ២០១៦

**ទីកន្លែងធ្វើការ:** ភ្នំពេញ

**មុខតំណែង:**

១. អ្នកមើលថែទារក និងមាតា (ចំនួន ៣០នាក់)

**លក្ខខណ្ឌជ្រើសរើស:**

- មានបទពិសោធន៍យ៉ាងតិច ១ឆ្នាំ
- មានចំណេះដឹងខាងមើលថែទាំ
- ត្រូវមានទំនួលខុសត្រូវលើការងារ

**សូមទំនាក់ទំនងតាមរយៈ:**

ផ្ទះលេខ១១ DA ផ្លូវ១៦៧ រាជធានីភ្នំពេញ (ជិតភោជនីយដ្ឋានម្លប់ស្វាយ៩៩ ទូតចិន)

☎ ០១៧ ៥៥៤ ៤៧៥

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

## ASEAN JOBS COMMUNITY ORGANIZATION

**ថ្ងៃផុតកំណត់:** ១៨ មេសា ២០១៦

**ទីកន្លែងធ្វើការ:** ភ្នំពេញ

**មុខតំណែង:**

១. អ្នកបើកឡានលក់ (ចំនួន ០៣នាក់)

២. អ្នកបើកបរ Tuk Tuk (ចំនួន ០៥នាក់)

**លក្ខខណ្ឌជ្រើសរើស:**

- មានបទពិសោធន៍ រឺគ្មានបទពិសោធន៍
- មានទំនាក់ទំនងល្អ
- អាចធ្វើការលក់ទៅតាមខេត្តបាន
- មានប័ណ្ណបើបររថយន្ត

**សូមទំនាក់ទំនងតាមរយៈ:**

ផ្ទះលេខ២០B ផ្លូវលេខ៣៧១ (ផ្លូវសឡា) សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ (ទល់មុខស្ថានីយទូរទស្សន៍បាយ័ន)

☎ ០១២ ៣៣៣ ៧៨២ /០៩៨ ៣៣៣ ៧៨២

✉ cvaseanjobs@gmail.com

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកកាន់ «មជ្ឈមណ្ឌលការងារ» ណាមួយរបស់ ទ.ជ.ម.ក ឬតាមរយៈគេហទំព័រ www.nea.gov.kh/jobshop

## ASEAN JOBS COMMUNITY ORGANIZATION

**ថ្ងៃផុតកំណត់:** ១៨ មេសា ២០១៦

**ទីកន្លែងធ្វើការ:** ភ្នំពេញ

**មុខតំណែង:**

១. អ្នកបើក Zazer (ចំនួន ០២នាក់)

**លក្ខខណ្ឌជ្រើសរើស:**

- មានបទពិសោធន៍ចាប់ពី ៣ឆ្នាំឡើង
- ព្យាយាមក្នុងការងារ
- មានទូទួលខុសត្រូវខ្ពស់ក្នុងការងារ

**សូមទំនាក់ទំនងតាមរយៈ:**

ផ្ទះលេខ២០B ផ្លូវលេខ៣៧១ (ផ្លូវសេឡា) សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ (ទល់មុខស្ថានីយទូរទស្សន៍បាយ័ន)

☎ ០១២ ៣៣៣ ៧៨២ /០៩៨ ៣៣៣ ៧៨២

✉ cvaseanjobs@gmail.com

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

## CamUP Job Agency

**ថ្ងៃផុតកំណត់:** ៣១ មីនា ២០១៦

**ទីកន្លែងធ្វើការ:** សៀមរាប

**មុខតំណែង:**

១. អ្នកសំអាត និងរៀបចំបន្ទប់ (ចំនួន ០២នាក់)

**លក្ខខណ្ឌជ្រើសរើស:**

- ទាំងពីរភេទ
- ព្យាយាមក្នុងការងារ
- មានទំនាក់ទំនងល្អក្នុងការងារ
- មានភាពស្មោះត្រង់
- អាចបត់បែនទៅតាមការងារបានគ្រប់ពេល

**សូមទំនាក់ទំនងតាមរយៈ:**

អគារ T&C ៣៥-៣៧ ជាន់ទី២ ផ្លូវ២១៤ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ

☎ ០១០ ៤៨៩ ៧៧៧/០១០ ៧៧៧ ២០៨

✉ cv2@camupjob.com

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

## CamUP Job Agency

**ថ្ងៃផុតកំណត់:** ២០ មេសា ២០១៦

**ទីកន្លែងធ្វើការ:** ភ្នំពេញ

**មុខតំណែង:**

១. បុគ្គលិក បម្រើការក្នុងភោជនីយដ្ឋាន (ចំនួន ០៨នាក់)

**លក្ខខណ្ឌជ្រើសរើស:**

- ទាំងពីរភេទ
- ត្រូវមានភាពរួសរាយរាក់ទាក់
- អាចប្រើប្រាស់ភាសាអង់គ្លេសបាន
- មិនទាមទារបទពិសោធន៍
- ចេះចំអិនអាហារបានខ្លះៗ
- ត្រូវមានភាពស្មោះត្រង់ និងមានការប្រាស្រ័យទាក់ទងល្អក្នុងកន្លែងការងារ
- ត្រូវមានភាពទទួលខុសត្រូវខ្ពស់

**សូមទំនាក់ទំនងតាមរយៈ:**

អគារ ធី អេន ស៊ី ជាន់ទី២ ផ្ទះលេខ ៣៥-៣៧ ផ្លូវសម្តេចប៉ាន២១៥ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ

☎ ០១០ ៤១៨ ៧៧៧ / ០១០ ៤៦១ ៧៧៧

✉ cv2@camupjob.com

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកកាន់ «មជ្ឈមណ្ឌលការងារ» ណាមួយរបស់ ទ.ជ.ម.ក ឬតាមរយៈគេហទំព័រ www.nea.gov.kh/jobshop

## Best Galaxy Import Export Co., Ltd

**ថ្ងៃផុតកំណត់:** ២០ មេសា ២០១៦

**ទីកន្លែងធ្វើការ:** សៀមរាប

**មុខតំណែង:**

១. បុគ្គលិក បម្រើការក្នុងភោជនីយដ្ឋាន (ចំនួន ០៨នាក់)

**លក្ខខណ្ឌជ្រើសរើស:**

- ទាំងពីរភេទ
- ត្រូវមានភាពរួសរាយរាក់ទាក់
- អាចប្រើប្រាស់ភាសាអង់គ្លេសបាន
- មិនទាមទារបទពិសោធន៍
- ចេះចំអិនអាហារបានខ្លះៗ
- ត្រូវមានភាពស្មោះត្រង់ និងមានការប្រាស្រ័យទាក់ទងល្អក្នុងកន្លែងការងារ
- ត្រូវមានភាពទទួលខុសត្រូវខ្ពស់

**សូមទំនាក់ទំនងតាមរយៈ:**

អគារ ជី អេន ស៊ី ជាន់ទី២ ផ្ទះលេខ ៣៥-៣៧ ផ្លូវសម្តេចប៉ាន២១៥ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ

☎ ០១០ ៤១៨ ៧៧៧ / ០១០ ៤៦១ ៧៧៧

✉ cv2@camupjob.com

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

## KMP Development Co., Ltd.

**ថ្ងៃផុតកំណត់:** ១២ មេសា ២០១៦

**ទីកន្លែងធ្វើការ:** ភ្នំពេញ

**មុខតំណែង:**

១. អ្នកបើឡាន (ចំនួន ០២នាក់)

**លក្ខខណ្ឌជ្រើសរើស:**

- មានប័ណ្ណបើកបរត្រឹមត្រូវ និងមានសុពលភាព
- មានបទពិសោធន៍ក្នុងការបើកបរ
- យល់ដឹងអំពីបច្ចេកទេសប្រើប្រាស់ឡាន
- ចេះច្បាប់ចរាចរណ៍ផ្លូវគោកនៃព្រះរាជាណាចក្រកម្ពុជា
- មានអត្តចរិកល្អសមរម្យទាំងពាក្យសំដៅ កាយវិការ និងការស្លៀកពាក់

**សូមទំនាក់ទំនងតាមរយៈ:**

ផ្ទះលេខ ៥៦ ផ្លូវលេខ ៣៣៧ សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ

☎ ០៧៧ ៦០៥ ២៥៥

✉ Hr-info@kmpkh.com

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

## INTERMEDICA Co., Ltd.

**ថ្ងៃផុតកំណត់:** ០៧ មេសា ២០១៦

**ទីកន្លែងធ្វើការ:** ភ្នំពេញ

**មុខតំណែង:**

១. អ្នកបើឡាន (ចំនួន ០៣នាក់)

**លក្ខខណ្ឌជ្រើសរើស:**

- ភេទប្រុស អាយុពី20-50ឆ្នាំ
- ចេះបើកបរឡាន និងមានបណ្ណ័បើកបរត្រឹមត្រូវ
- ចេះអានឯកសារ ដូចជា វិកយ័បត្រ័ បណ្ណ័បញ្ចេញទំនិញ ជាអក្សរឡាតាំង
- មានចរិកស្លូតបូត ស្មោះត្រង់

**សូមទំនាក់ទំនងតាមរយៈ:**

ផ្ទះលេខ២៥៤ ផ្លូវ៥៩៨ ខណ្ឌទួលគោក រាជធានីភ្នំពេញ

☎ ០១២ ៦៦៦ ៨៩៧

✉ home@intermed.com.kh

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកកាន់ «មជ្ឈមណ្ឌលការងារ» ណាមួយរបស់ ទ.ជ.ម.ក ឬតាមរយៈគេហទំព័រ www.nea.gov.kh/jobshop

## ក្រុមហ៊ុន Blue Midea

**ថ្ងៃផុតកំណត់:** ២០១៥

**ទីកន្លែងធ្វើការ:** ភ្នំពេញ

**មុខតំណែង:**

១. បុគ្គលិកផ្នែកទីផ្សារ(ភេទប្រុស)

២. ជាងជួសជុល និងតំឡើងម៉ាស៊ីនត្រជាក់

៣. ចុងភៅ(ភេទស្រី)

**លក្ខខណ្ឌជ្រើសរើស:**

- ត្រូវមានយានជំនិះផ្ទាល់ខ្លួន អាចសេសេរ និយាយ ស្តាប់ ភាសាចិន ឬភាសាអង់គ្លេសបានល្អ(អ្នកចេះចិនមានអទិភាព)
- មិនមានបទពិសោធន៍ក៏អាចធ្វើការបានដែរ
- ត្រូវចេះដំឡើងម៉ាស៊ីន 1HP ឡើងទៅ
- អាចធ្វើម្ហូបចិនបានច្រើនមុខ
- មានភាពអត់ធ្មត់ក្នុងការងារ

**សូមទំនាក់ទំនងតាមរយៈ:**

☎ ០២៣ ២១៨ ៦១៣

✉ hoklay.so@bluemidea.com/ sohoklay.bluehill@gmail.com

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

## ក្រុមហ៊ុន ធិនីម៉ិច

**ថ្ងៃផុតកំណត់:** ២០១៥

**ទីកន្លែងធ្វើការ:** ភ្នំពេញ

**មុខតំណែង:**

១. បុគ្គលិកផ្នែកឃ្លាំង (ចំនួន ០៥នាក់)

២. បុគ្គលិកផ្នែករដ្ឋបាល និងធនធានមនុស្ស

៣. បុគ្គលិកផ្នែកទីផ្សារ(ប្រធានផ្នែក)

**លក្ខខណ្ឌជ្រើសរើស:**

- ចេះបើកបរ កម្រិតវប្បធម៌ចប់បាក់ឌុប
- មានកម្រិតវប្បធម៌បញ្ចប់បរិញ្ញាប័ត្រឬកំពុងបន្តថ្នាក់បរិញ្ញាប័ត្រ
- មានបទពិសោធន៍ផ្នែករដ្ឋបាល HR យ៉ាងតិច១ឆ្នាំ
- មានការប្តេជ្ញាចិត្ត និងការអត់ធ្មត់ខ្ពស់ក្នុងការងារ
- មានរូបសម្បត្តិសមរម្យ មានភាពរួសរាយរាក់ទាក់។

**សូមទំនាក់ទំនងតាមរយៈ:**

ផ្ទះលេខ២២៤៥, ផ្លូវទេពផន, សង្កាត់ ទឹកល្អក់២, ខណ្ឌ ទួលគោក, រាជធានីភ្នំពេញ

☎ ០២៣ ៨៩៧ ៧២៥

✉ info@dhinimex.com

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

## ក្រុមហ៊ុន ឡាម៉ូស

**ថ្ងៃផុតកំណត់:** ២០១៥

**ទីកន្លែងធ្វើការ:** ភ្នំពេញ

**មុខតំណែង:**

១. បុគ្គលិកផ្នែកទីផ្សារ (ភេទស្រី ០៣នាក់)

**លក្ខខណ្ឌជ្រើសរើស:**

- ត្រូវមានភាពអត់ធ្មត់ និងមានទំនួលខុសត្រូវក្នុងការងារ
- ផ្តល់អាទិភាពចំពោះអ្នកអាចចុះតាមខេត្តបាន

**សូមទំនាក់ទំនងតាមរយៈ:**

☎ ០១២៨២ ១៨ ២៨/០១៥ ៦១១ ៦១១

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

## ក្រុមហ៊ុន តាន់ហ្វូត

**ថ្ងៃផុតកំណត់:** ២០១៥

**ទីកន្លែងធ្វើការ:** ភ្នំពេញ

**មុខតំណែង:**

១. បុគ្គលិកផ្នែកទីផ្សារ



តទៅទំព័របន្ទាប់

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកកាន់ «មជ្ឈមណ្ឌលការងារ» ណាមួយរបស់ ទ.ជ.ម.ក ឬតាមរយៈគេហទំព័រ www.nea.gov.kh/jobshop

២. បុគ្គលិកផ្នែករដ្ឋបាល
៣. គណនេយ្យករ
៤. បុគ្គលិកផ្នែកគ្រប់គ្រង
៥. បុគ្គលិកផ្នែកទំនាក់ទំនង

**លក្ខខណ្ឌជ្រើសរើស:**

**សូមទំនាក់ទំនងតាមរយៈ:**

ផ្ទះលេខ១១២F, ផ្លូវលេខ២៧១, សង្កាត់ ទំនប់ទឹក, ខណ្ឌមានជ័យ, រាជធានីភ្នំពេញ

☎ ០៨១ ៧២ ៨៤ ៨៥/០១២ ២៤៨ ៨២៨/០៩៦ ៣៥ ៨៣ ១២៣

tanfood@yahoo.com

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

## ក្រុមហ៊ុន ហ៊្វេត ខា

**ថ្ងៃផុតកំណត់:** ២០១៥

**ទីកន្លែងធ្វើការ:** ភ្នំពេញ

**មុខតំណែង:**

១. ប្រធានផ្នែកលក់ (ចំនួន ០២នាក់)
២. អ្នកតំណាងផ្នែកលក់ (ចំនួន ០៦នាក់)

**លក្ខខណ្ឌជ្រើសរើស:**

- មានសញ្ញាប័ត្រ ឬបរិញ្ញាប័ត្រផ្នែកទីផ្សារ ឬមានតម្លៃស្មើ
- មានបទពិសោធន៍ទាក់ទង និងផ្នែកលក់យ៉ាងហោចណាស់១ឆ្នាំ
- ធ្លាប់ធ្វើការនៅក្រុមហ៊ុនលក់គ្រឿងសំណង់(មានអាទិភាព)
- មានភាពស្មោះត្រង់ចំពោះការងារ
- មានភាពរួសរាយរាក់ទាក់ និងប៉ិនប្រសព្វក្នុងការទំនាក់ទំនងភ្ញៀវ
- មានភាពរហ័សរហួន ម្ចាស់ការ និងចេះទទួលខុសត្រូវលើការងាររបស់ខ្លួន

**សូមទំនាក់ទំនងតាមរយៈ:**

ផ្ទះលេខ ៣២០ ផ្លូវ២៧១ សុកហុកសង្កាត់បឹងទំពន់ ខណ្ឌមានជ័យ រាជធានីភ្នំពេញ

ផ្ទះលេខ ២២៣A ផ្លូវ៥៩៨ សង្កាត់បឹងទំពន់ ខណ្ឌ មានជ័យ រាជធានីភ្នំពេញ

☎ ០១៦ ៦០០០៦០/០៩២ ១១១១៣០

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

## ក្រុមហ៊ុន Reliance Worldwide International Ltd

**ថ្ងៃផុតកំណត់:** ២០១៥

**ទីកន្លែងធ្វើការ:** ភ្នំពេញ

**មុខតំណែង:**

១. បុគ្គលិកផ្នែកលក់ និងទីផ្សារ (ទាំងពីរភេទ)

**លក្ខខណ្ឌជ្រើសរើស:**

- ត្រូវចេះភាសាអង់គ្លេស/ខ្មែរ
- មានជំនាញក្នុងការទំនាក់ទំនង និងមានភាពក្លាហាន
- មានបទពិសោធន៍ការងារយ៉ាងតិចមួយឆ្នាំ

**សូមទំនាក់ទំនងតាមរយៈ:**

☎ ០៨៨ ៥៩ ៥៦ ៧៥១

relianceworld88@gmail.com

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

## ក្រុមហ៊ុន ខ្មែរ អនុស្សា ខបអើរសេិន

**ថ្ងៃផុតកំណត់:** ២០១៥

**ទីកន្លែងធ្វើការ:** ភ្នំពេញ

**មុខតំណែង:**

១. បុគ្គលិកផ្នែកគណនេយ្យ និងរដ្ឋបាល

**លក្ខខណ្ឌជ្រើសរើស:**

- មានជំនាញគណនេយ្យ និងបែបបទរដ្ឋបាល

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកកាន់ «មជ្ឈមណ្ឌលការងារ» ណាមួយរបស់ ទ.ជ.ម.ក ឬតាមរយៈគេហទំព័រ www.nea.gov.kh/jobshop

- ចេះកម្មវិធី Word &Excel
- ចេះភាសាអង់គ្លេស(ឬភាសាចិនកាន់តែប្រសើរ)

**សូមទំនាក់ទំនងតាមរយៈ:**

ផ្ទះលេខ២, ផ្លូវទេពបុរី១០០ខ្នង, សង្កាត់ ទឹកថ្លា, ខណ្ឌ ចំការមន, រាជធានីភ្នំពេញ

☎ ០៦៦ ៨១ ៩៩៩៩/០១២ ៥២២២ ៤៤

van_lyheang@yahoo.com

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

## ក្រុមហ៊ុន B.C INTERNATIONL TRADING Co., Ltd

**ថ្ងៃផុតកំណត់:** ២០១៥

**ទីកន្លែងធ្វើការ:** ភ្នំពេញ

**មុខតំណែង:**

១. តំណាងផ្នែកលក់តាមខេត្ត (ចំនួន ០៣នាក់)
២. តំណាងផ្នែកលក់ភ្នំពេញតាម TUK TUK (ចំនួន ០២នាក់)
៣. អ្នកដឹកជញ្ជូន(ចំនួន ០២នាក់)
៤. អ្នករចនាគេហទំព័រ(ស្ម័គ្រចិត្តចំនួន ០២នាក់)
៥. ប្រធានផ្នែកលក់(ចំនួន ០២នាក់)
៦. អ្នកកាន់ស្តុក (ចំនួន ០៣នាក់)

**លក្ខខណ្ឌជ្រើសរើស:**

**សូមទំនាក់ទំនងតាមរយៈ:**

☎ ០១៦ ៣៨ ៥៤ ០៧/០៨៩ ៧៣ ៣៨ ២២

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

## ស្ថាបនា លីមីតធីត

**ថ្ងៃផុតកំណត់:** ២៥ កញ្ញា ២០១៥

**ទីកន្លែងធ្វើការ:** តាមបណ្តាខេត្ត

**មុខតំណែង:**

១. ភ្នាក់ងារឥណទាន
២. ជាវី
៣. ជំនួយការរដ្ឋបាល
៤. ជំនួយការទីផ្សារ

**លក្ខខណ្ឌជ្រើសរើស:**

- បរិញ្ញាប័ត្រគណនេយ្យ ហិរញ្ញវត្ថុ ធនាគារ រដ្ឋបាល ទីផ្សារ ឬសញ្ញាប័ត្រដែលមានតម្លៃស្មើ
- មានចំណេះដឹងភាសាអង់គ្លេសអាចប្រើការបាន
- ចំណេះដឹង Ms Office អាចប្រើការបាន
- មានអាកប្បកិរិយាល្អ ស្មោះត្រង់ រួសរាយរាក់ទាក់ មានភាពអំណត់ កាយសម្បទាមាំមួន និងមានទំនួលខុសត្រូវក្នុងការងារ
- យល់ដឹងពីផលិតផល និងសេវារបស់ស្ថាប័នហិរញ្ញវត្ថុ ដូចជាគ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ និងធនាគារ

**សូមទំនាក់ទំនងតាមរយៈ:**

ផ្ទះលេខ ៨៣១c ផ្លូវ មហាវិថីព្រះមុនីវង្ស សង្កាត់ផ្សារដើមថ្កូវ ខណ្ឌ ចំការមន រាជធានីភ្នំពេញ

☎ ០៨១ ៨២៧ ៩២៧

«ឬ សូមទំនាក់ទំនងដោយផ្ទាល់មកកាន់មជ្ឈមណ្ឌលការងារណាមួយរបស់ ទ.ជ.ម.ក»

## ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
## Ministry of Labour and Vocational Training
## វិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា
## National Polytechnic Institute of Cambodia

**អាហារូបករណ៍ពិសេស**

និស្សិតនារី : ទទួលបានការបញ្ចុះតម្លៃ ៣០%
និស្សិតលេខ ១ : ទទួលបានអាហារូបករណ៍ប្រចាំឆ្នាំ ១០០%
និស្សិតលេខ ២ : ទទួលបានអាហារូបករណ៍ប្រចាំឆ្នាំ ៣០%
និទ្ទេស A : ទទួលបានអាហារូបករណ៍ ១០០%
និទ្ទេស B : ទទួលបានអាហារូបករណ៍ ៥០%
និទ្ទេស C : ទទួលបានអាហារូបករណ៍ ៣០%

### មានបណ្តុះបណ្តាលលើជំនាញ

- វិស្វករអគ្គិសនី
- វិស្វករមេកានិក
- វិស្វករសំណង់ស៊ីវិល
- វិស្វករអេឡិចត្រូនិក
- ភាសាកូរ៉េ
- គ្រប់គ្រងបច្ចេកវិទ្យា
- វិទ្យាសាស្ត្រកុំព្យូទ័រ
- វិជ្ជាជីវៈគណនេយ្យ
- អក្សរសាស្ត្រអង់គ្លេស
- ទេសចរណ៍ និងបដិសណ្ឋារកិច្ច

### និស្សិតនឹងទទួលបាន

- ការប្រើប្រាស់ប្រព័ន្ធ អ៊ិនធើណេត និង WiFi ដោយឥតគិតថ្លៃក្នុងបរិវេណរបស់វិទ្យាស្ថានសម្រាប់ធ្វើការសិក្សាស្រាវជ្រាវ ។
- មានអន្តេវាសិកដ្ឋានដ៏ធំទូលាយសម្រាប់និស្សិតមកពីតាមខេត្តក្រុងនានា ។
- សេវាកម្មរថយន្តដឹកជញ្ជូននិស្សិតដែលស្នាក់នៅក្នុងក្រុងភ្នំពេញ ។
- មានអ្នកជំនាញការជាតិ និងអន្តរជាតិ នៅគ្រប់មហាវិទ្យាល័យ ។
- សាស្ត្រាចារ្យខ្មែរមានសញ្ញាបត្រ អនុបណ្ឌិត,បណ្ឌិត និងបទពិសោធន៍យូរឆ្នាំ ។
- រាល់កម្មវិធីសិក្សាស្របតាមតម្រូវការទីផ្សារស្តង់ដាជាតិ និងអន្តរជាតិ ។
- បន្ទប់ទ្រឹស្តី និងអនុវត្តន៍មានឧបករណ៍សម្ភារៈប្រើប្រាស់តាមបច្ចេកវិទ្យាទំនើប ។

### ម៉ោងសិក្សា

- ថ្ងៃចន្ទ ដល់ សុក្រ (០៨.០០-១២.០០ និង ១៣.០០-១៦.០០)
- ថ្នាក់បន្តវិស្វករ ឬបរិញ្ញាបត្របច្ចេកវិទ្យា
  ថ្ងៃសៅរ៍-អាទិត្យ ០៨.០០-១២.០០ និង ១៣.០០-១៧.០០
- ម.វិ វិទ្យាសាស្ត្រកុំព្យូទ័រ និងម.វិ ទេសចរណ៍ និងបដិសណ្ឋារកិច្ច
  វេនព្រឹក ថ្ងៃចន្ទ ដល់ ថ្ងៃសុក្រ ០៨.០០-១២.៣០
  វេនរសៀល ថ្ងៃចន្ទ ដល់ ថ្ងៃសុក្រ១៣.០០-១៧.៣០

### អាសយដ្ឋាន

- ភូមិព្រៃពពេល សង្កាត់សំរោងក្រោម ខណ្ឌពោធិ៍សែនជ័យ ភ្នំពេញ(ក្បែរវត្តពូនភ្នំ)
- (023) 96 15 193 / 010 970 351 / 012 381 246 / 011 769 003
- www.npic.edu.kh ,Email: npicinfo@gmail.com


## វិទ្យាស្ថាន NPIC ប្រារព្ធពិធីខួប ១០ឆ្នាំ

វិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជាបានប្រារព្ធខួប ១០ឆ្នាំ នៃថ្ងៃបង្កើតវិទ្យាស្ថានកាលពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ក្នុងនេះមានភ្ញៀវដែលជាដៃគូរសហប្រតិបត្តិការជាតិ អន្តរជាតិ និងក្រសួងស្ថាប័នពាក់ព័ន្ធមួយចំនួនបានចូលរួម ។ ឯកឧត្តម ពេជ សោភ័ន រដ្ឋលេខាធិកាក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៃព្រះរាជាណាចក្រកម្ពុជាបានអញ្ជើញបានចូលរួមជាអធិបតីភាពក្នុងកម្មវិធី និងបានសម្ពោធពិធីតាំងបង្ហាញនូវពិព័ណ៌ស្នាដៃនិស្សិតដែលមកពីគ្រប់មហាវិទ្យាល័យរបស់វិទ្យាស្ថានដែលនេះបង្ហាញពីចំណេះដឹងផ្នែកទ្រឹស្តីផ្សាភ្ជាប់កាអនុវត្តន៍ជាក់ស្តែងរបស់និស្សិតរទៅតាមកំរិត និងតាមជំនាញនិមួយៗរបស់និស្សិតវិទ្យាស្ថាន ។

គួររំលឹកផងដែរថា វិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា ជាគ្រឹះស្ថានអប់រំរបស់រដ្ឋដែលធំជាងគេនៅក្នុងប្រទេសកម្ពុជាដែលបានសាងសង់ឡើងក្រោមជំនួយកម្ចីសហប្រតិបត្តិការរវាងកម្ពុជា និងកូរ៉េខាងត្បូងហើយបានដាក់សម្ពោធឲ្យប្រើប្រាស់តាំងពីឆ្នាំ២០០៥ ។




## ទស្សនកិច្ចសិក្សារបស់សិស្សវិទ្យាល័យនៅក្នុងវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជាឆ្នាំ ២០១៥

សិស្សានុស្សិសថ្នាក់ទី១២ របស់វិទ្យាល័យចំនួន ១៣ ដែលឋិតនៅក្នុងនិងជុំវិញរាជធានីភ្នំពេញត្រូវបានអនុញ្ញាត្តិឲ្យមកធ្វើទស្សនកិច្ចសិក្សាក្នុងវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជាចាប់ពីខែមិថុនា-កក្កដា ឆ្នាំ ២០១៥ ។ គោលបំណងសំខាន់ក្នុងដំណើរទស្សនកិច្ចសិក្សានេះគឺ វិទ្យាស្ថានចង់បង្ហាញនិងណែនាំប្អូនៗសិស្សានុស្សិសឲ្យយល់ដឹងពីសារៈសំខាន់ក្នុងការសិក្សាមុខជំនាញបច្ចេកទេសដែលជាជំនាញដែលកំពុងមានតម្រូវការខ្ពស់ឆ្លើយតបទៅតាមតម្រូវការចំបាច់លើទីផ្សារការងារក្នុងពេលបច្ចុប្បន្ន និងដើម្បីចូលរួមចំនែកអភិវឌ្ឍន៍សង្គមកម្ពុជាតាមរយៈការសិក្សាជំនាញបច្ចេកទេស ។




## បទបង្ហាញក្រុមហ៊ុន SOMA Group អំពីយន្តហោះ Drone ដល់និស្សិតអេឡិចត្រូនិកនៃវិទ្យាស្ថាន NPIC

បន្ទាប់ពីមានជំនួបពិភាក្សារវាងតំណាងរបស់ក្រុមហ៊ុន SOMA GROUP ជាមួយតំណាងរបស់វិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជាកាលពីថ្ងៃទី០៥ ខែមិថុនាឆ្នាំ២០១៥ រួចមកក្រុមហ៊ុន SOMA GROUP បានរៀបចំសិក្ខា-សាលា( Workshop ) មួយដែលបានប្រព្រឹត្តិទៅ ៦ថ្ងៃក្រោយជំនួបពិភាក្សារវាងដៃគូសហប្រតិបត្តិការទាំងពីខាងលើ ។ គោលបំណងសំខាន់របស់សិក្ខាសាលានេះគឺផ្តោតលើបច្ចេកវិទ្យាយន្តហោះប្រភេទ Drone និងផ្តល់ឱកាសការងារជា Drone Pilot នៅក្នុងក្រុមហ៊ុនឲ្យដល់និស្សិតផ្នែកអេឡិចត្រូនិកនៃវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា ។





សូមមេត្តារង់ចាំទស្សនា
ទីភ្នាក់ងារជាតិមុខរបរ និងការងារ
NATIONAL EMPLOYMENT AGENCY
នាទី
ទីផ្សារការងារ និង មុខរបរ
នៅលើកញ្ចក់ទូរទស្សន៍:
អង្គារ 22h
ពុធ 17h
សុក្រ 10h:45mn
សុក្រ 10h
សៅរ៍ 11h
សៅរ៍ 11h
សៅរ៍ 12h
សៅរ៍ 14h
សៅរ៍/អាទិត្យ 13h
អាទិត្យ 10h/17h
TV3
SEATV
CNC
APSARA
PPCTV
CCTV
ឬលើគេហទំព័រ
www.nea.gov.kh

## ដៃគូសហការសំខាន់ៗ

ត្រូវការ

# ការងារ ឬ បុគ្គលិក

សេវាសម្រាប់

## អ្នកស្វែងរកការងារ

- ការចុះឈ្មោះស្វែងរកការងារធ្វើ និងផ្សព្វផ្សាយប្រវត្តិរូបសង្ខេបដោយងាយស្រួល និងទូលំទូលាយ
- ព័ត៌មានជ្រើសរើសបុគ្គលិក និងការអប់រំបណ្តុះបណ្តាលគ្រប់ប្រភេទ
- ការជួយស្វែងរកការងារធ្វើគ្រប់ប្រភេទ និងទូលំទូលាយជាងគេបំផុត
- ការផ្គូផ្គង និងបញ្ជូនអ្នកស្វែងរកការងារធ្វើទៅឱ្យនិយោជក
- ការណែនាំអំពីឱកាសការងារ និងការវាយតម្លៃអំពីលទ្ធភាពទទួលបានការងារ
- ការណែនាំអំពីការត្រៀមលក្ខណៈស្វែងរកការងារធ្វើ ឱកាសការងារ និងការអភិវឌ្ឍអាជីព
- ព័ត៌មានទីផ្សារការងារទូទៅ



សេវាសម្រាប់

## និយោជក

- ការផ្សព្វផ្សាយព័ត៌មានជ្រើសរើសបុគ្គលិកដោយងាយស្រួល និងបានទូលំទូលាយជាងគេបំផុត
- ការផ្តល់ធនាគារទិន្នន័យអំពីអ្នកស្វែងរកការងារធ្វើគ្រប់ប្រភេទនិងច្រើនជាងគេបំផុត
- ការផ្តល់ទីតាំងការិយាល័យសម្រាប់ជ្រើសរើសបុគ្គលិក
- ការផ្គូផ្គង និងបញ្ជូនអ្នកស្វែងរកការងារធ្វើគ្រប់ប្រភេទដោយងាយស្រួល
- ការចុះដល់ទីកន្លែងរបស់និយោជកផ្ទាល់ដើម្បីប្រមូលព័ត៌មានជ្រើសរើសបុគ្គលិក
- ការណែនាំអំពីការជ្រើសរើសបុគ្គលិក
- ព័ត៌មានទីផ្សារការងារទូទៅ



លោកអ្នកអាចទាញយកកម្មវិធី NEA JOB SEARCH ពី Google play | NEA JOB SEARCH | ANDROID APP ON Google play

www.nea.gov.kh

National Employment Agency

### ម.ភ រាជធានីភ្នំពេញ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១
ខណ្ឌទួលគោក រាជធានីភ្នំពេញ
023 633 6002 ឬ 077 232 378 ឬ016 786 655
jc_pp@nea.gov.kh

### ម.ភ ខេត្តបាត់ដំបង

វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែន
បាត់ដំបង ផ្លូវលេខ២០១ ភូមិព្រែកមហាទេព
សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង
053 733 111 ឬ 016 926 655
jc_battambang@nea.gov.kh

### ម.ភ ខេត្តកំពត

វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែន
កំពត ភូមិ០១ ឧសភា សង្កាត់កំពង់កណ្តាល
ក្រុងកំពត
033 210 277 ឬ 016 506 655
jc_kampot@nea.gov.kh

### ម.ភ ខេត្តកំពង់ចាម

មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ
ខេត្តកំពង់ចាម ផ្លូវលេខ៧ចាស់ ភូមិទី៧
សង្កាត់កំពង់ចាម ក្រុងកំពង់ចាម
042 210 277 ឬ 016 656 655
jc_kampongcham@nea.gov.kh

### ម.ភ ខេត្តសៀមរាប

វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែន
សៀមរាប សង្កាត់ស្លក្រាម
ក្រុងសៀមរាប
063 210 277ឬ 016 536 655
jc_siemreap@nea.gov.kh

### ម.ភ ខេត្តស្វាយរៀង

វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែន
ស្វាយរៀង ភូមិមេភ្លើង សង្កាត់ស្វាយរៀង
ក្រុងស្វាយរៀង
044 715 277 ឬ 016 646 655
jc_svayrieng@nea.gov.kh

### ម.ភ ខេត្តកំពង់ធំ

មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ
ខេត្តកំពង់ធំ ភូមិអាចារ្យលាក់ សង្កាត់
អាចារ្យលាក់ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ
062 210 277 / 016 836 655
jc_kampongthom@nea.gov.kh

### ម.ភ ខេត្តព្រៃវែង

មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ
ខេត្តព្រៃវែង ភូមិ១សង្កាត់កំពង់លាវ
ក្រុងព្រៃវែង ខេត្តព្រៃវែង
081 786 655 / 043 210 277
jc_preyveng@nea.gov.kh

### ម.ភ ខេត្តតាកែវ

វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែន
តាកែវ ក្នុងភូមិ៣ សង្កាត់រការក្នុង ក្រុងដូនកែវ
ខេត្តតាកែវ
032 210 277 ឬ 016 676 655
jc_takeo@nea.gov.kh

